# កញ្ញា ឆេង ដានោ



> *“យើងត្រូវផ្តល់តម្លៃដល់ស្រ្តីដែលជាឆ្អឹងខ្នងរបស់ប្រទេសមួយ ពីព្រោះការរីកចម្រើននៃវិស័យឧស្សាហកម្មមិនអាចទៅរួចទេ ដោយពុំមានការចូលរួមពីស្រ្តី។ ចំពោះស្រ្តីទាំងអស់ អ្នកមិនទន់ខ្សោយទេ”!*

កញ្ញា ឆេង ដានោ អាយុ ៤៤ ឆ្នាំជាសកម្មជនសិទ្ធិការងារប្រមាណជាង៩ ឆ្នាំមកហើយ។ ទន្ទឹមនឹងនោះកញ្ញាគឺជាអនុប្រធានសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភណ្ឌកាត់ដេរកម្ពុជា។ កញ្ញាធ្លាប់ធ្វើជាកម្មករកាត់ដេរអស់រយៈពេល ១៣ ឆ្នាំ (១៩៩៨-២០១១)។ កញ្ញាមិនដែលធ្លាប់គិតថាកញ្ញានឹងក្លាយជាសកម្មជនម្នាក់ទេ ពីព្រោះកញ្ញាពុំមានចំណេះដឹងក្នុងការតស៊ូមតិ។ ទោះយ៉ាងណា នៅឆ្នាំ២០១៣ កញ្ញាបានបង្កើតសហជីពមួយនៅរោងចក្រយ៉ុនស៊ីនហើយក៏បានក្លាយជាប្រធានសហជីព។ ដោយសារកញ្ញាឃើញភាពលំបាកជាច្រើនបានកើតឡើងលើកម្មករ កញ្ញាបានសម្រេចចិត្តចូលរួមធ្វើសកម្មភាពផ្សេងៗ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិការងារតាមរយៈការតស៊ូមតិ ដើម្បីទទួលបានការគាំទ្រពីរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត។ ជាលទ្ធផលនៃការខិតខំតស៊ូមតិរបស់កញ្ញា បានធ្វើឱ្យលក្ខខណ្ឌការងារបានប្រសើរឡើងមួយចំនួនដូចជា ប្រាក់អតីតភាព ប្រាក់ខែចុងក្រោយ ប្រាក់បំណាច់បណ្តេញចេញ និងប្រាក់ជូនដំណឹងជាមុនជាដើម។ល។

ទន្ទឹមនឹងភាពជោគជ័យ កញ្ញាត្រូវប្រឈមនឹងការរឹតត្បិត និងបៀតបៀនដោយអាជ្ញាធរមូលដ្ឋាន អ្នកមានអំណាច និងសហគមន៍របស់កញ្ញាផងដែរក្នុងអំឡុងពេលធ្វើការងារ។ ក្នុងនាមជាស្រ្តី និងសកម្មជនម្នាក់ សិទ្ធិរបស់កញ្ញាត្រូវបានរារាំងដោយអាជ្ញាធរមូលដ្ឋាន និងសហគមន៍មិនឱ្យកញ្ញាបានសម្រេចគោលដៅ។ លើសពីនេះទៀត កញ្ញាត្រូវបានហាមឃាត់មិនឱ្យអនុវត្តសកម្មភាព ដោយនិយាយថាបេសកកម្មការងារមិនអាចទៅរួច រួមទាំងការសូកប៉ាន់ និងគំរាមកំហែងដល់សន្តិសុខរបស់កញ្ញាផងដែរ។

ភាពងាយរងគ្រោះ និងការភ័យខ្លាចរបស់កម្មករកាត់ដេរចំពោះការបាត់បង់ការងារ ការរឹតត្បិតសេរីភាពក្នុងការប្រាស្រ័យទាក់ទងជាមួយសហសេវិកដោយសេរី និងការបង្កើតសហជីព ការកម្រិតសិទ្ធិក្នុងការចេញទៅខាងក្រៅដើម្បីប្រជុំប្រសិនគ្មានលិខិតអញ្ជើញត្រឹមត្រូវ រួមទាំងចំណេះដឹងទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិការងារ និងច្បាប់នានា បាននាំឱ្យកម្មកររោងចក្រកាត់ដេរស្ថិតនៅក្នុងភាពស្ងាត់ស្ងៀម និងស៊ូទ្រាំនឹងការលំបាក។ ហេតុដូច្នេះហើយ កញ្ញាចង់លើកកម្ពស់ និងការពារសិទ្ធិរបស់កម្មករកាត់ដេរដើម្បីទទួលបាននូវអត្ថប្រយោជន៍ និងសេរីភាពពេញលេញក្នុងនាមជាមនុស្សជាតិ និងជានិយោជិកស្របច្បាប់ការងាររបស់ពួកគេ។

កញ្ញាបានឈរលើគោលជំហរយ៉ាងម៉ឺងម៉ាត់ថា នៅតែបន្តការពារ និងលើកកម្ពស់សមភាពយេនឌ័រ ជាពិសេសផ្តល់ការពង្រឹងសិទ្ធិអំណាចដល់ស្ត្រីដែលងាយរងគ្រោះ ដើម្បីឱ្យពួកគេទទួលបានអត្ថប្រយោជន៍ និងការយកចិត្តទុកដាក់ស្មើគ្នាពីនិយោជករបស់ពួកគេ។

ចំពោះកញ្ញា សមភាពយេនឌ័រមានន័យថា សមភាពរវាងបុរស និងស្ត្រីក្នុងវិស័យការងារ។ មានន័យថា បុរសនិងស្ត្រីគឺស្មើគ្នា ក្នុងការទទួលបានឱកាសការងារដូចគ្នា ការទូទាត់ និងអត្ថប្រយោជន៍ដូចគ្នា និងការយកចិត្តទុកដាក់ដូចគ្នាពីសំណាក់និយោជក៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

cc BY NC SA

ខែធ្នូ ឆ្នាំ២០១៩